Australian Government
Department of Health, Disability and Ageing



# ច្បាប់ថ្មីស្ដីពីការថែទាំមនុស្សចាស់ដោយផ្ដោតលើសិទ្ធិ

ច្បាប់ថ្មីស្ដីពីការថែទាំមនុស្សចាស់នឹងផ្ដោតអាទិភាពលើសិទ្ធិរបស់មនុស្សចាស់។ ច្បាប់នេះរួមមាន Statement of Rights [សេចក្ដីថ្លែងការណ៍ស្ដីពីសិទ្ធិរបស់មនុស្សចាស់] ក្នុងការទទួលយកសេវាកម្មថែទាំមនុស្សចាស់។ សន្លឹកព័ត៌មាននេះគឺជាសេចក្ដីសង្ខេបជាភាសាសាមញ្ញអំពីសិទ្ធិទាំងនោះ។

## អំពីសេចក្ដីថ្លែងការណ៍ស្ដីពីសិទ្ធិ

រដ្ឋាភិបាលអូស្ត្រាលីកំពុងធ្វើការផ្លាស់ប្ដូរច្បាប់ស្ដីពីការថែទាំមនុស្សចាស់របស់ប្រទេសអូស្ត្រាលី។ Aged Care Act 2024 *[ច្បាប់ស្ដីពីការថែទាំមនុស្សចាស់ឆ្នាំ 2024]* (ច្បាប់ថ្មី) រួមមានសេចក្ដីថ្លែងការណ៍ស្ដីពីសិទ្ធិ។ សេចក្ដីថ្លែងការណ៍នេះពន្យល់ពីសិទ្ធិទាំងឡាយដែលមនុស្សចាស់មានក្នុងការទទួលយកសេវាកម្មថែទាំមនុស្សចាស់ឧបត្ថម្ភដោយរដ្ឋាភិបាលអូស្ត្រាលី។ សេចក្ដីថ្លែងការណ៍ស្ដីពីសិទ្ធិនេះនឹងជំនួសធម្មនុញ្ញបច្ចុប្បន្នស្ដីពីសិទ្ធិថែទាំមនុស្សចាស់នៅថ្ងៃទី 1 ខែវិច្ឆិកា ឆ្នាំ 2025។

សេចក្ដីថ្លែងការណ៍ពេញលេញស្ដីពីសិទ្ធិដែលដកស្រង់ចេញពីច្បាប់ថ្មីនេះមាននៅផ្នែកចុងសន្លឹកព័ត៌មាននេះ។

## តើសេចក្ដីថ្លែងការណ៍ស្ដីពីសិទ្ធិនេះមានន័យដូចម្ដេចសម្រាប់អ្នក

សេចក្ដីថ្លែងការណ៍ស្ដីពីសិទ្ធិនឹងជួយធានាថាអ្នកគឺជាចំណុចកណ្ដាលនៃការថែទាំមនុស្សចាស់។

វាផ្ដល់ឱ្យអ្នកនូវសិទ្ធិ៖

- ធ្វើការសម្រេចចិត្តផ្ទាល់ខ្លួនអំពីជីវិតរបស់អ្នក
- មិនត្រឹមធ្វើឱ្យគេទទួលយកការសម្រេចចិត្តរបស់អ្នកប៉ុណ្ណោះទេ ប៉ុន្តែតែត្រូវបានគេគោរពការសម្រេចចិត្តរបស់អ្នក
- ទទួលបានព័ត៌មាន និងការគាំពារផ្សេងៗដើម្បីជួយអ្នកធ្វើការសម្រេចចិត្ត
- ប្រាប់ពីបំណង តម្រូវការ និងចំណង់ចំណូលចិត្តរបស់អ្នក
- ទទួលបានសុវត្ថិភាព និងត្រូវបានគេគោរព
- ឱ្យគេគោរពវប្បធម៌ និងអត្តសញ្ញាណរបស់អ្នក
- រក្សាទំនាក់ទំនងជាមួយសហគមន៍របស់អ្នក។

## ឯករាជ្យភាព ជម្រើស និងការគ្រប់គ្រង

អ្នកមានសិទ្ធិធ្វើការសម្រេចចិត្តខ្លួនឯង និងមានការគ្រប់គ្រងលើ៖

- សេវាកម្មថែទាំមនុស្សចាស់ដែលផ្តល់មូលនិធិអ្វីខ្លះដែលអ្នកប្រើប្រាស់
- របៀបដែលអ្នកទទួលបានសេវាកម្មថែទាំមនុស្សចាស់ដែលផ្តល់មូលនិធិ និងនរណាផ្តល់សេវាកម្មទាំងនោះ
- ថវិកា និងសម្ភារៈផ្ទាល់ខ្លួនរបស់អ្នក។

អ្នកមានសិទ្ធិទទួលបានការគាំទ្រក្នុងការសម្រេចចិត្តទាំងនេះប្រសិនបើអ្នកត្រូវការ។

អ្នកក៏មានសិទ្ធិក្នុងការជ្រើសរើសរបៀបដែលអ្នករស់នៅ សូម្បីតែមានហានិភ័យផ្ទាល់ខ្លួនខ្លះក៏ដោយ។ ឧទាហរណ៍ ជម្រើសនានាអំពីជីវិតក្នុងសង្គម និងទំនាក់ទំនងជិតស្និទ្ធរបស់អ្នក។

## សិទ្ធិចូលប្រើប្រាស់ដោយយុត្តិធម៌

អ្នកមានសិទ្ធិទទួលបានការវាយតម្លៃដ៏ត្រឹមត្រូវ និងដោយយុត្តិធម៌ដើម្បីកំណត់ថាតើសេវាកម្មថែទាំមនុស្សចាស់ដែលផ្តល់មូលនិធិអ្វីខ្លះដែលអ្នកត្រូវការ។

ការវាយតម្លៃនេះត្រូវតែធ្វើទៅតាមវិធីដែលសមត្រូវនឹងអ្នក។ វាក៏គួរតែគោរព៖

- ប្រវត្តិ និងវប្បធម៌របស់អ្នក
- បទពិសោធន៍ផ្ទាល់ខ្លួន និងការប៉ះទង្គិចណាមួយប្រសិនបើមាន
- ស្ថានភាពយល់ដឹងនានាដូចជា ជំងឺវង្វេងស្មារតី។

អ្នកក៏មានសិទ្ធិទទួលបានប្រភេទនៃការថែទាំដែលអ្នកត្រូវការ និងនៅពេលណាដែលអ្នកត្រូវការវា។ នេះរួមមានការថែទាំបំបាត់ការឈឺចាប់ និងការថែទាំនៅ-ចុងបញ្ចប់-អាយុជីវិត។

## សុវត្ថិភាព និងគុណភាព

អ្នកមានសិទ្ធិទទួលបានសេវាកម្មថែទាំមនុស្សចាស់ដែលផ្តល់មូលនិធិប្រកបដោយគុណភាព មានសុវត្ថិភាព និងដោយយុត្តិធម៌ ដែលប្រព្រឹត្តមកលើអ្នកប្រកបដោយភាពថ្លៃថ្នូរ និងការគោរព។

នេះរួមមានសិទ្ធិទទួលបានសេវាកម្មថែទាំមនុស្សចាស់ដែលផ្តល់មូលនិធិដែល ៖

- ផ្តល់គុណតម្លៃ និងគាំពារដល់អត្តសញ្ញាណ វប្បធម៌ និងប្រវត្តិរបស់អ្នក
- គោរពបទពិសោធន៍របស់អ្នក រួមមានការប៉ះទង្គិចផ្លូវចិត្តណាមួយ
- អាចចូលប្រើប្រាស់បាន និងបំពេញតាមសេចក្តីត្រូវការរបស់អ្នក
- គ្មានហិង្សា ការរំលោភបំពាន និងការធ្វេសប្រហែស។

អ្នកមានសិទ្ធិទទួលបានសេវាកម្មថែទាំមនុស្សចាស់ដែលផ្តល់មូនិធិពី៖

- បុគ្គលិកបំពេញការងារដែលមានការបណ្តុះបណ្តាល ជំនាញ និងបទពិសោធន៍ត្រឹមត្រូវ
- អ្នកផ្តល់សេវាកម្មនានាដែលបំពេញតាមគ្រប់លក្ខខណ្ឌទាំងអស់នៅក្រោមច្បាប់ថែទាំមនុស្សចាស់។

ប្រសិនបើអ្នកមានអារម្មណ៍ថាគ្មានសុវត្ថិភាពនៅពេលចូលប្រើប្រាស់សេវាកម្មថែទាំមនុស្សចាស់ អ្នកអាចទទួលបានការគាំទ្រដោយមិនគិតថ្លៃពីមេធាវី បុគ្គលិកសង្គមកិច្ច និងអ្នកជំនាញផ្សេងទៀត។ សូមចូលមើលគេហទំព័រអគ្គមេធាវីសម្រាប់ព័ត៌មានបន្ថែមអំពីការការពារប្រឆាំងនឹងការរំលោភបំពានលើមនុស្សចាស់។

### គោរពឯកជនភាព និងព័ត៌មានរបស់អ្នក

អ្នកផ្តល់សេវាកម្មរបស់អ្នកត្រូវតែ ៖

- គោរពឯកជនភាពផ្ទាល់ខ្លួនរបស់អ្នក
- ការពារព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកដូចជាព័ត៌មានអំពីសុខភាព និងថវិការបស់អ្នក
- អនុញ្ញាតឱ្យអ្នកជ្រើសរើសពេលណាដែលព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកអាចផ្តល់ជូនទៅនរណាម្នាក់ទៀត ដូចជាអ្នកតស៊ូមតិ ឬមេធាវី។

អ្នកមានសិទ្ធិទទួលបានកំណត់ត្រា និងព័ត៌មានអំពីសិទ្ធិរបស់អ្នក និងសេវាកម្មថែទាំមនុស្សចាស់ដែលផ្តល់មូលនិធិដែលអ្នកប្រើប្រាស់។ នេះរួមមានថាតើសេវាកម្មនោះថ្លៃប៉ុន្មាន។

### ការទំនាក់ទំនងដែលបំពេញតាមតម្រូវការរបស់អ្នក

អ្នកមានសិទ្ធិ៖

- ទទួលបានព័ត៌មានក្នុងលំនាំដែលអ្នកអាចយល់បាន
- ផ្តល់មតិកែលម្អ។

អ្នកមានសិទ្ធិធ្វើការទំនាក់ទំនងដោយប្រើភាសា ឬវិធីសាស្ត្រដែលអ្នកចូលចិត្ត។ នេះរួមមានការប្រើសេវាកម្មអ្នកបកប្រែផ្ទាល់មាត់ ឬជំនួយផ្នែកទំនាក់ទំនងប្រសិនបើអ្នកត្រូវការវា។

អ្នកក៏មានសិទ្ធិជួបជាមួយអ្នកផ្តល់សេវាកម្ម និងអ្នកគាំទ្ររបស់អ្នកតាមវិធីដែលសមស្របសម្រាប់អ្នកផងដែរ។ នេះមានន័យថាការប្រជុំតាមពេលវេលាដែលសមស្របបំផុតសម្រាប់អ្នក។

### ការគាំទ្រដើម្បីលើកបញ្ហាឱ្យបានលឿន និងប្រកបដោយយុត្តិធម៌

ពេលណាមានបញ្ហានានាពាក់ព័ន្ធនឹងសេវាកម្មថែទាំមនុស្សចាស់ដែលផ្តល់មូលនិធិ អ្នកមានសិទ្ធិ៖

- ទទួលបានការគាំទ្រពីអ្នកផ្តល់សេវាកម្មរបស់អ្នក
- ធ្វើការប្តឹងតវ៉ាដោយគ្មានការភ័យខ្លាច ឬការដាក់ទណ្ឌកម្ម
- ទទួលបានការឆ្លើយតបយ៉ាងឆាប់រហ័ស និងប្រកបដោយយុត្តិធម៌លើបណ្តឹងតវ៉ារបស់អ្នក។

### ការគាំទ្រ និងការភ្ជាប់ទំនាក់ទំនងជាមួយមនុស្ស និងសហគមន៍

អ្នកអាចត្រូវការជំនួយដើម្បីស្វែងយល់ពីសិទ្ធិរបស់អ្នក ធ្វើការសម្រេចចិត្តនានា ឬធ្វើបណ្តឹងតវ៉ា។ អ្នកមានសិទ្ធិទទួលបានការគាំទ្រនេះពីអ្នកតស៊ូមតិឯករាជ្យ ឬជនណាម្នាក់ផ្សេងទៀតដែលអ្នកជ្រើសរើស។

អ្នកមានសិទ្ធិទំនាក់ទំនងជាមួយអ្នកតស៊ូមតិរបស់អ្នក ឬបុគ្គលគាំទ្ររបស់អ្នកពេលដែលអ្នកចង់បាន។

អ្នកផ្តល់សេវាកម្មនានាត្រូវតែគោរពតួនាទីរបស់មនុស្សដែលមានសារៈសំខាន់ចំពោះអ្នក។ ឧទាហរណ៍ គ្រួសារ មិត្តភ័ក្រ ឬអ្នកថែទាំ។

អ្នកមានសិទ្ធិរក្សាទំនាក់ទំនងជាមួយ៖

- មនុស្សដែលមានសារៈសំខាន់ចំពោះអ្នក
- សហគមន៍របស់អ្នក រួមមានការចូលរួមក្នុងសកម្មភាពកំសាន្ត ឬសកម្មភាពវប្បធម៌នានា
- សត្វចិញ្ចឹមរបស់អ្នក។

ជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait មានសិទ្ធិរក្សាទំនាក់ទំនងជាមួយសហគមន៍ ទឹកដី និងកោះកំណើតរបស់គេ។

## របៀបធានាថាសិទ្ធិរបស់អ្នកត្រូវបានគេគោរព

អ្នកផ្តល់សេវាកម្មរបស់អ្នកត្រូវតែយល់ និងគោរពតាមសេចក្តីថ្លែងការណ៍ស្តីពីសិទ្ធិ។ ប្រសិនបើពួកគេមិនធ្វើទេ អ្នកអាចប្តឹងទៅកាន់ស្នងការទទួលពាក្យបណ្តឹង។

អ្នកអាចធ្វើបណ្តឹងតវ៉ាតាមអនឡាញ តាមទូរសព្ទ ឬដោយសរសេរសំបុត្រ។ សូមមើលគេហទំព័រគណៈកម្មការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពការថែទាំមនុស្សចាស់សម្រាប់ព័ត៌មានបន្ថែម។

ប្រសិនបើអ្នកត្រូវការជំនួយដើម្បីធ្វើបណ្ដឹងតវ៉ា ឬស្វែងរកព័ត៌មានផ្សេងៗ សូមទូរសព្ទទៅកាន់ Older Persons Advocacy Network (OPAN) តាមលេខ 1800 700 600។

OPAN មានអ្នកតស៊ូមតិឯករាជ្យ រក្សាការសម្ងាត់ និងមិនគិតកម្រៃដើម្បីជួយអ្នក។

## សេចក្ដីថ្លែងការពេញលេញស្ដីពីសិទ្ធិពីច្បាប់ថ្មី

ខាងក្រោមនេះគឺជាសេចក្ដីថ្លែងការណ៍ស្ដីពីសិទ្ធិចាប់ពីផ្នែកទី 23 នៃច្បាប់ថ្មី។

*ឯករាជ្យភាព ភាពម្ចាស់ការ ការផ្ដល់សិទ្ធិអំណាច និងសេរីភាពក្នុងការជ្រើសរើស*

(1) បុគ្គលម្នាក់ៗមានសិទ្ធិ៖
- (a) ជ្រើសរើស និងធ្វើការសម្រេចចិត្តដែលប៉ះពាល់ដល់ជីវិតរបស់បុគ្គលម្នាក់ៗ រួមមានការពាក់ព័ន្ធនឹងចំណុចដូចខាងក្រោមនេះ
  - (i) សេវាកម្មថែទាំមនុស្សដែលផ្ដល់មូលនិធិដែលបុគ្គលនោះទទួលបានការអនុម័តដើម្បីចូលប្រើប្រាស់
  - (ii) វិធី ពេលវេលា និងថាតើសេវាកម្មទាំងនោះត្រូវផ្ដល់ឱ្យដោយនរណាទៅដល់បុគ្គលនោះ
  - (iii) កិច្ចការហិរញ្ញវត្ថុរបស់បុគ្គល និងភាពជាម្ចាស់កម្មសិទ្ធិលើសម្ភារៈផ្ទាល់ខ្លួន និង
- (b) ទទួលបានជំនួយ (ប្រសិនបើចាំបាច់) ដើម្បីធ្វើការសម្រេចចិត្តទាំងនោះ និងឱ្យមានការគោរពទៅតាមការសម្រេចចិត្តទាំងនោះ និង
- (c) ទទួលយកហានិភ័យផ្ទាល់ខ្លួន រួមមានការព្យាយាមស្វែងរកគុណភាពជីវិត ការចូលរួមក្នុងសង្គម និងទំនាក់ទំនងជិតស្និទ្ធ ហើយនិងទំនាក់ទំនងផ្លូវភេទរបស់បុគ្គល។

*សមភាពក្នុងការចូលប្រើប្រាស់*

(2) បុគ្គលម្នាក់ៗមានសិទ្ធិចូលប្រើប្រាស់ប្រកបដោយសមធម៌៖
- (a) ដើម្បីឱ្យតម្រូវការរបស់បុគ្គលសម្រាប់សេវាកម្មថែទាំមនុស្សចាស់ដែលផ្ដល់មូលនិធិត្រូវបានវាយតម្លៃ ឬវាយតម្លៃឡើងវិញ តាមវិធីដែល៖
  - (i) សមស្របតាមវប្បធម៌ និងមានសុវត្ថិភាពតាមវប្បធម៌ ដោយមានការយល់ដឹងអំពី-ការប៉ះទង្គិចផ្លូវចិត្ត និងជ្រាបព័ត៌មានសព្វគ្រប់អំពី-ការព្យាបាល និង
  - (ii) អាចចូលប្រើប្រាស់បាន និងមានភាពសមស្របសម្រាប់បុគ្គលម្នាក់ៗដែលកំពុងរស់នៅជាមួយនឹងជម្ងឺវង្វេងស្មារតី ជំងឺប៉ះពាល់ដល់ការយល់ដឹង និង
- (b) ការថែទាំបំបាត់ការឈឺចាប់ ការថែទាំនៅចុងបញ្ចប់-ជីវិត-ពេលណាត្រូវការ។

*ទទួលបានសេវាកម្មថែទាំមនុស្សចាស់ដែលផ្ដល់មូលនិធិប្រកបដោយសុវត្ថិភាព និងគុណភាព*

(3) បុគ្គលម្នាក់ៗមានសិទ្ធិ៖
- (a) ទទួលបានការយកចិត្តទុកដាក់ប្រកបដោយភាពថ្លៃថ្នូរ និងការគោរព និង
- (b) ទទួលបានការយកចិត្តទុកដាក់ប្រកបដោយសុវត្ថិភាព សមភាព និងគ្មាន-ការរើសអើង និង
- (c) ទទួលបានការផ្ដល់គុណតម្លៃ និងគាំទ្រលើអត្តសញ្ញាណ វប្បធម៌ សាសនា និងភាពចម្រុះរបស់បុគ្គល និង
- (d) សេវាកម្មថែទាំមនុស្សចាស់ដែលផ្ដល់មូលនិធិកំពុងត្រូវបានផ្ដល់ទៅដល់បុគ្គលម្នាក់ៗ៖
  - (i) តាមវិធីដែលសមស្រប និងមានសុវត្ថិភាពស្របតាមវប្បធម៌ ដោយមានការយល់ដឹងពី-ការប៉ះទង្គិចផ្លូវចិត្ត និងការព្យាបាល-បន្ទាប់ពីជ្រាបព័ត៌មានសព្វគ្រប់ និង
  - (ii) តាមវិធីដែលអាចចូលប្រើប្រាស់បាន និង
  - (iii) ផ្ដល់ជូនដោយបុគ្គលិកថែទាំរបស់សេវាកម្មនានាដែលបានចុះបញ្ជីស្របច្បាប់ដែលមានសញ្ញាបត្រ ជំនាញ និងបទពិសោធន៍សមស្រប។

(4) បុគ្គលម្នាក់ៗមានសិទ្ធិ៖
- (a) រួចផុតពីទម្រង់នៃអំពើហិង្សាគ្រប់ប្រភេទ ការបន្ទាបបន្ថោក ឬការប្រព្រឹត្តិដោយអមនុស្សធម៌ ការកេងប្រវ័ញ្ច មិនអើពើ ការបង្ខិតបង្ខំ អំពើរំលោភបំពាន ឬអំពើផ្លូវភេទ និង
- (b) ទទួលបានសេវាកម្មថែទាំមនុស្សចាស់ដែលផ្ដល់មូលនិធិប្រកបដោយគុណភាព សុវត្ថិភាព ដែលផ្ដល់ជូនជាប់ជាប្រចាំ ដោយដាក់ឱ្យអនុលោមតាមតម្រូវការនានាដល់អ្នកផ្ដល់សេវាកម្មដែលបានចុះបញ្ជីស្របច្បាប់នៅក្រោមច្បាប់នេះ។

កំណត់ចំណាំ៖ ភាគទី 1 នៃផ្នែកទី4 ជំពូកទី 3 រៀបរាប់ពីលក្ខខណ្ឌនានាដែលតម្រូវឱ្យអ្នកផ្ដល់សេវាកម្មដែលបានចុះបញ្ជីស្របច្បាប់ រួមមានតម្រូវការពាក់ព័ន្ធនឹងការប្រើប្រាស់ការអនុវត្តដោយមានដែនកំណត់លើការគ្រប់គ្រងឧប្បត្តិហេតុ។

*គោរពឯកជនភាព និងព័ត៌មាន*

(5) បុគ្គលម្នាក់ៗមានសិទ្ធិ៖
 (a) ឱ្យគេគោរពឯកជនភាពផ្ទាល់ខ្លួន និង
 (b) ទទួលបានការការពារព័ត៌មានផ្ទាល់ខ្លួន។

(6) បុគ្គលម្នាក់ៗមានសិទ្ធិស្វែងរក និងទទួលបានការផ្ដល់ជូននូវកំណត់ត្រា និងព័ត៌មានអំពីសិទ្ធិបុគ្គលនៅក្រោមផ្នែកនេះ និងសេវាកម្មថែទាំមនុស្សចាស់ដែលផ្ដល់មូលនិធិដែលបុគ្គលម្នាក់ៗទទួលបាន រួមមានតម្លៃនៃសេវាកម្មទាំងនោះ។

*ការទំនាក់ទំនងដោយផ្ដោតលើបុគ្គល និងលទ្ធភាពក្នុងការលើកឡើងបញ្ហាផ្សេងៗដោយគ្មានការផ្ដាញ់តប*

(7) បុគ្គលម្នាក់ៗមានសិទ្ធិ៖
 (a) ទទួលបានការជូនដំណឹងតាមវិធីដែលបុគ្គលម្នាក់ៗអាចយល់ អំពីសេវាកម្មថែទាំមនុស្សចាស់ដែលផ្ដល់មូលនិធិដែលបុគ្គលនោះប្រើប្រាស់ និង
 (b) បញ្ចេញមតិពីសេវាកម្មថែទាំមនុស្សចាស់ដែលផ្ដល់មូលនិធិដែលបុគ្គលនោះប្រើប្រាស់ ហើយត្រូវបានគេស្ដាប់មតិទាំងនោះ។

(8) បុគ្គលម្នាក់ៗមានសិទ្ធិទំនាក់ទំនងដោយប្រើភាសា ឬវិធីសាស្ត្រទំនាក់ទំនងដែលបុគ្គលនោះចូលចិត្ត ដោយអាចទទួលបានអ្នកបកប្រែផ្ទាល់មាត់ និងជំនួយផ្នែកទំនាក់ទំនងនានាពេលត្រូវការ។

(9) បុគ្គលម្នាក់ៗមានសិទ្ធិ៖
 (a) ទទួលបានការទំនាក់ទំនងដោយបើកចំហ និងការគាំទ្រពីអ្នកផ្ដល់សេវាកម្មដែលបានចុះបញ្ជីស្របច្បាប់ នៅពេលកើតមានបញ្ហាក្នុងការផ្ដល់សេវាកម្មថែទាំមនុស្សចាស់ដែលផ្ដល់មូលនិធិ និង
 (b) ធ្វើបណ្ដឹងតវ៉ាដោយប្រើយន្តការដែលអាចចូលប្រើប្រាស់បាន ដោយគ្មានការភ័យខ្លាចការផ្ដាញ់តប ការផ្ដល់សេវាកម្មថែទាំមនុស្សចាស់ដែលផ្ដល់មូលនិធិដល់បុគ្គលនោះ និង
 (c) ទទួលបានការដោះស្រាយបណ្ដឹងដោយឆាប់រហ័ស និងប្រកបដោយយុត្តិធម៌។

*អ្នកតស៊ូមតិ មនុស្សសំខាន់ និងការទំនាក់ទំនងសង្គម*

(10) បុគ្គលម្នាក់ៗមានសិទ្ធិទទួលបានជំនួយពីអ្នកតស៊ូមតិ ឬជំនួយពីបុគ្គលផ្សេងទៀតតាមការជ្រើសរើសរបស់ពួកគេ រួមមានពេលអនុវត្តសិទ្ធិ ឬស្វែងយល់ពីសិទ្ធិរបស់គេនៅក្នុងផ្នែកនេះ ការបញ្ចេញមតិរបស់បុគ្គលម្នាក់ៗ ធ្វើការសម្រេចចិត្តដែលប៉ះពាល់ដល់ជីវិតរបស់បុគ្គលម្នាក់ៗ ការធ្វើបណ្ដឹងតវ៉ា ឬការផ្ដល់មតិកែលម្អ។

(11) បុគ្គលម្នាក់ៗមានសិទ្ធិទទួលបានការទទួលស្គាល់ និងគោរពដល់តួនាទីរបស់បុគ្គលដែលមានសារៈសំខាន់ដល់បុគ្គលនោះ រួមមានអ្នកថែទាំ ភ្ញៀវ និងអ្នកស្ម័គ្រចិត្ត។

(12) បុគ្គលម្នាក់ៗមានសិទ្ធិទទួលបានឱកាស និងជំនួយដើម្បីរក្សាទំនាក់ទំនង

 (ប្រសិនបើបុគ្គលនោះជ្រើសរើសបែបនេះ) ជាមួយ៖
 (a) បុគ្គលដែលមានសារៈសំខាន់ដល់បុគ្គលនោះ និងសត្វចិញ្ចឹមរួមមានការទៅលេងសួរសុខទុក្ខដោយសុវត្ថិភាពពីសមាជិកគ្រួសារ មិត្តភ័ក្រ អ្នកស្ម័គ្រចិត្ត ឬភ្ញៀវផ្សេងទៀត ដែលជីវិតរបស់បុគ្គលនោះ និងការទៅលេងសួរសុខទុក្ខពីសមាជិកគ្រួសារ និង
 (b) សហគមន៍របស់បុគ្គលនោះ រួមមានការចូលរួមក្នុងជីវិតសាធារណៈ និងសកម្មភាពកំសាន្តវប្បធម៌ សាសនា និងរបៀបរស់នៅ និង
 (c) ប្រសិនបើបុគ្គលនោះជាជនជាតិដើម Aboriginal ឬអ្នកកោះ Torres Strait -សហគមន៍ ទឹកដី និងកោះកំណើត។

(13) បុគ្គលម្នាក់ៗមានសិទ្ធិចូលប្រើប្រាស់បានគ្រប់ពេលដែលបុគ្គលជ្រើសរើស មនុស្សដែលបានចាត់តាំងដោយបុគ្គល ឬមនុស្សដែលបានចាត់តាំងដោយអាជ្ញាធរសមស្រប។

**Copyright**

© 2025 Commonwealth of Australia as represented by the Department of Health, Disability and Ageing

**Licence (except for Commonwealth logos)**

This publication is licensed under a Creative Commons Attribution-Non-Commercial 4.0 International Licence from https://creativecommons.org/licenses/by-nc/4.0/legalcode.en. This Licence does not include, and no permission is given for, the use of the Commonwealth logos contained in this publication.

**Disclaimer**

This publication is not legal advice and must not to be used or relied upon as a substitute for legal advice. Users must seek their own independent legal advice in relation to their particular circumstances.